ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ច័ន្ទ ០៤ រោច ខែ ស្រាពណ៍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី

ជំនួបសម្តែងការគួរសម និងជម្រាបលារបស់ឯកឧត្តម Hidehisa HORINOUCHI ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជាមួយ
ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យឯកឧត្តម **Hidehisa HORINOUCHI** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបសម្តែងការគួរសម និងជម្រាបលា ក្នុងខណៈដែលឯកឧត្តមនឹងត្រូវបញ្ចប់អាណត្តិនៃការបំពេញបេសកកម្មការទូត ក្នុងរយៈពេលបីឆ្នាំ (ឆ្នាំ២០១៦-ឆ្នាំ២០១៩) នៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលជប៉ុន ដែលតែងតែរក្សា និងបានផ្តល់នូវកិច្ចសហប្រតិបត្តិការល្អប្រសើរសម្រាប់កម្ពុជា និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **Hidehisa HORINOUCHI** ក្នុងអាណត្តិការទូត ដែលឯកឧត្តមបានបំពេញភារកិច្ច និងតួនាទីយ៉ាងសំខាន់ជួយដល់ការអភិវឌ្ឍប្រទេសកម្ពុជា ដោយសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន ទាំងក្នុងទំនាក់ទំនងការទូត កិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន និងបានរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកម្ពុជា ។

ក្នុងអាណត្តិបីឆ្នាំនៃការបំពេញបេសកកម្មការទូតនៅកម្ពុជានេះ, កម្ពុជា-ជប៉ុន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ (Japan ODA) មានទឹកប្រាក់សរុបប្រមាណជាង ៥៥០ លានដុល្លារអាមេរិក ក្នុងនោះ ហិរញ្ញប្បទានឥតសំណងមានទឹកប្រាក់ប្រមាណជិត ១៥០ លានដុល្លារអាមេរិកសម្រាប់គាំទ្រលើវិស័យជាច្រើនរួមមាន÷ ផ្លូវ, ស្ពាន, ការផ្គត់ផ្គង់ទឹកស្អាត, ថាមពលអគ្គិសនី, អប់រំ, សុខាភិបាល និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា និងទឹកប្រាក់ប្រមាណជាង ៤០០ លានដុល្លារអាមេរិក ជាឥណទានសម្បទានសម្រាប់ហិរញ្ញប្បទានបន្ថែម ដល់គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ ៥ (ស្ពានព្រែកក្តាម-ក្រុងបោយប៉ែត) គម្រោងអភិវឌ្ឍន៍ចំណតកុងតែន័រកំពង់ផែស្វយ័តក្រុងព្រះ

សីហនុ, គម្រោងស្ដារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយអគ្គិសនី ។ល។ វិភាគទានរបស់ប្រជាជនជប៉ុន សុទ្ធសឹងតែគាំទ្រដល់យុទ្ធសាស្ត្រនៃការអភិវឌ្ឍជាតិរបស់កម្ពុជា ។

ជាមួយគ្នានេះ, សម្រាប់ឆ្នាំ ២០១៨, ទំហំនៃការវិនិយោគឯកជនពីប្រទេសជប៉ុន មានទឹកប្រាក់ប្រមាណ ៤៤០ លានដុល្លារអាមេរិក ។ រីឯការនាំចេញទៅប្រទេសជប៉ុន មានទំហំទឹកប្រាក់ប្រមាណ ១ ៦០០ លានដុល្លារអាមេរិក ។ គិតត្រឹមឆមាសទី ១ ឆ្នាំ ២០១៩, ទំហំនៃការវិនិយោគ និងពាណិជ្ជកម្មជប៉ុន មានទឹកប្រាក់កើនឡើងប្រមាណជិត ៥០០ លានដុល្លារអាមេរិក រីឯការនាំចេញទៅប្រទេសជប៉ុន មានទំហំទឹកប្រាក់ប្រមាណជាង ១ ៧០០ លានដុល្លារអាមេរិក ។

ឯកឧត្តមឯកអគ្គរដ្ឋទូត Hidehisa HORINOUCHI បានសម្ដែងនូវសេចក្ដីសោមនស្សរីករាយ ដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា និងកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងរីកចម្រើនស្ទើរគ្រប់វិស័យ ។ រដ្ឋាភិបាលជប៉ុន នឹងបន្តពង្រឹង និងពង្រីកទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការនានាលើគ្រប់វិស័យអាទិភាពជាមួយកម្ពុជា រួមទាំងបន្តគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍ, ការវិនិយោគសាធារណៈ និងឯកជននានានៅកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានជូនពរឱ្យឯកឧត្តម Hidehisa HORINOUCHI ទទួលបាននូវជោគជ័យសម្រាប់ការបំពេញភារកិច្ចថ្មីបន្តទៀត ។